## សេចក្តីសង្ខេប


មូលនិធិភាពជាដៃគូសំរាប់ ប្រព័ន្ធអេកូឡូស៊ីដែលរងការគម្រាមកំហែង (CEPF) ត្រូវបានបង្កើតឡើងដើម្បីធានាសុវត្ថិភាព នៃភាពសំបូរបែបនៃជីវសាស្ត្រ ពិភពលោក តំបន់ដែលរងការគម្រាមកំហែងដ៏ច្រើនលើសលុប ហើយត្រូវបានស្គាល់ ថាជាតំបន់ជីវៈចំរុះហាតស្ពត (Biodiversity hotspots) ។ CEPF ត្រូវបានផ្តួចផ្តើមបង្កើត រួមគ្នាដោយ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) អង្គការអភិរក្សអន្តរជាតិ (CI) មូលនិធិបរិស្ថាន ពិភពលោក (GEF) រដ្ឋាភិបាលជប៉ុន មូលនិធិម៉ាករថ័រ (John D. and Catherine T. MacArthur) និងធនាគារពិភពលោក។

គោលបំណងសំខាន់នៃមូនិធិ CEPF គឺដើម្បីភ្ជាប់ទំនាក់ទំនងរវាងសង្គមស៊ីវិល ដូចជាក្រុមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល (NGO) ស្ថាប័នសិក្សាធិកា និង សហគ្រាសឯកជននានានៅក្នុងការអភិរក្សជីវៈចំរុះ ក្នុងតំបន់ហាតស្ពត។ ដើម្បីធានា ដល់ភាពជោគជ័យរបស់ពួកគេ ការខិតខំប្រឹងប្រែងទាំងនេះត្រូវបានបំពេញបន្ថែមលើកម្មវិធី និងយុទ្ធសាស្ត្រដែលមានស្រាប់របស់រដ្ឋាភិបាលជាតិ និងផ្នែកផ្តល់ជំនួយផ្នែក អភិរក្សនានា។ នៅក្នុងគោលបំណងនេះ, CEPF លើកកំពស់ការភ្ជាប់ទំនាក់ទំនងការងារក្នុងចំណោមក្រុមផ្សេងៗគ្នា ប្រមូលផ្តុំសមត្ថភាពពិសេសៗ និងកាត់បន្ថយសកម្មភាពការងារត្រួតគ្នាជាទ្រង់ទ្រាយធំ ហើយក៏បានធ្វើការដោះស្រាយសម្របសម្រួល ដើម្បីការងារអភិរក្ស។ មធ្យោបាយមួយដែល CEPF ធ្វើការងារនេះគឺតាមរយៈការរៀបចំនៃ “ឯកសារស្តីពីប្រព័ន្ធអេកូឡូស៊ី”៖ ការចែករំលែកយុទ្ធសាស្ត្របានបង្កើតឡើងនៅ ក្នុងការប្រឹក្សាជាមួយអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ដែលកំណត់យ៉ាងច្បាស់នូវផែនការយុទ្ធសាស្ត្រប្រាំឆ្នាំត្រូវបានផ្តល់ពត៌មានដោយការវិភាគស្ថានភាពយ៉ាងលំអិត។

ឯកសារស្តីពីប្រពន្ធ័អេកូឡូស៊ី បានឆ្លុះបញ្ជាំងទិដ្ឋភាពជាទូទៅនៃតំបន់ឥណ្ឌូភូមារហាតស្ពត ដែលដាក់បញ្ចូលតំបន់មិនមែនជាដែនសមុទ្រទាំងអស់របស់កម្ពុជា សាធារណៈរដ្ឋប្រជាមានិតឡាវ ភូមា ថៃ ហើយនិងវៀតណាម និងបូកបន្ថែមផ្នែកខ្លះនៃ ភាគខាងត្បូងប្រទេសចិន។ ជាមួយនឹងកំរិតដ៏ខ្ពស់នៃរុក្ខជាតិ និងសត្វដែលមានយ៉ាង កម្រដោយតំបន់ ហើយនិងទីជីរកធម្មជាតិនៅសេសសល់មានកំរិត ឥណ្ឌូភូមាស្ថិត ក្នុងចំណោមតំបន់ជិវៈចំរុះហាតស្ពតសំខាន់ៗជាងគេទាំង១០ សំរាប់ភាពដែលមិនអាច ជំនួសបាន និងស្ថិតនៅក្នុងចំណោមក្បាលតារាងទាំង៥ ដែលរងការគម្រាមកំហែង។ តំបន់ឥណ្ឌូភូមារមានប្រជាជានច្រើនជាងតំបន់ហាតស្ពតដ៏ទៃទៀតហើយវា ទ្រទ្រង់នូវ ប្រព័ន្ធអេកូឡូស៊ីដ៏សំបូរបែប ហើយត្រូវបានកាត់បន្ថយយ៉ាងសម្បើមរួចបាត់ទៅហើយ លើវិសាលភាពរបស់វា គឺវាអាស្រ័យលើសម្ពាធកើនឡើយយ៉ាងខ្លាំងក្លាពីការបាត់បង់

ទីជំរក ការបំផ្លិចបំផ្លាញ ការធ្វើឲ្យជាបំនែកតូចៗ និងការរុករកហួសប្រមាណនៃធនធានធម្មជាតិនានា។

## ការធ្វើបច្ចុប្បន្នភាពប្រព័ន្ធអេកូឡូស៊ី

CEPF បានកំពុងផ្តល់មូលនិធិដល់ក្រុមសង្គមស៊ីវិលនានា នៅក្នុងតំបន់ឥណ្ឌូភូមាហាតស្ពតចាប់តាំងពីឆ្នាំ២០០៨មក ត្រូវបានតំរង់ទិសដោយឯកសារស្តីអំពីប្រព័ន្ធអេកូឡូស៊ី ដែលត្រូវបានបង្កើតឡើតាមរយៈដំណើរការពិគ្រោះប្រឹក្សានៅក្នុងឆ្នាំ២០០៣។ ផ្នែកជាច្រើនត្រូវបានផ្លាស់ប្តូរចាប់តាំងពីទម្រង់ឯកសារដើមត្រូវបានរៀបចំ។ ជាពិសេសមានបំរែបម្រួលសំខាន់ៗមួយចំនួនទៅលើធម្មជាតិ និងទំនាក់ទំនងសំខាន់ៗនៃការគម្រាមកំហែងដល់ជីវៈចំរុះ ហើយនិងផលលំបាកចំនួនបួន-ប្រាំ បានលេចឡើងគឺមិនមែនជាភាគតូចនៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ដំណាំកសិ-ឧស្សាហកម្ម ការរុករករ៉ែ និង បម្រែបម្រួលអាកាសធាតុនោះទេ។ លើសពីនេះទៅទៀត មានបំលាស់ប្តូរសំខាន់ៗនៅក្នុងគំរូ នៃការវិនិយោគលើការងារអភិរក្ស ជាមួយនិងការអភិរក្សជីវៈចំរុះជាលក្ខណៈប្រពៃណីមួយចំនួន បណ្តាម្ចាស់ជំនួយកំពុងធ្វើកាណែនាំជាថ្មីពីកម្មវិធីរបស់ពួកគេទៅនឹងសកម្មភាពអាទិភាពដ៏ទៃទៀត ឬ ត្រូវបោះបង់ចោលតំបន់ទាំងស្រុង។ ជាងនេះទៅទៀត ទីតាំងប្រតិបត្តិដែលអាចប្រើប្រាស់បានសំរាប់សង្គមស៊ីវិល បានពង្រីកនៅក្នុងប្រទេសច្រើនបំផុត ហើយកំពុងបង្កើតឲ្យមានឱកាសជាច្រើនសំរាប់ថ្នាក់-ជាតិ មូលដ្ឋាន និងក្រុមបាតក្រោម ដើម្បីជំរុញនៅក្នុងកិច្ចខិតខំប្រឹងប្រែងលើការងារអភិរក្ស។ ជាចុងក្រោយ ការវិនិយោគដោយ CEPF និងប្រភពជំនួយដ៏ទៃទៀត បានកសាងវេទិកាដ៏រឹងមាំមួយនៃលទ្ធផលការងារអភិរក្ស ការអនុវត្តន៍ដ៏ល្អ ពត៌មាន និងសមត្ថភាពដែលអាច ត្រូវបានកសាងខាងលើ។

នៅក្នុងខែមេសាឆ្នាំ ២០១១ CEPF រួមជាមួយមូលនិធិម៉ាកាធឺរ (MacArthur Foundation) មូលនិធិម៉ាហ្គា រ៉េត អេ ខាហ្គិល (Margaret A. Cargill Foundation) និងមូលនិធិមាកណាយ (McKnight Foundation) ដើម្បីពិភាក្សាលើផលប្រយោជន៍រួមជាមួយការគោរពលើការសម្របសម្រួលការវិនិយោគរបស់ពួកគេក្នុងសង្គមស៊ីវិល នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលតំបន់ឥណ្ឌូភូមាហាតស្ពតត្រួតស៊ីគ្នាយ៉ាងធំធេង។ បន្ទាប់មកម្ចាស់ជំនួយចំនួនបួន បានយល់ព្រមដើម្បីធ្វើបច្ចុប្បន្នកម្មមូលនិធិនៃទំរង់ឯកសារប្រព័ន្ធអេកូឡូស៊ី។ ដំណើរការធ្វើបច្ចុប្បន្នភាពបានចាប់ផ្តើមនៅក្នុងខែមិថុនា ឆ្នាំ ២០១១ ហើយត្រូវបានបញ្ចប់នៅក្នុងខែមករា ឆ្នាំ ២០១២។

ដំណើរការធ្វើបច្ចុប្បន្នភាពត្រូវបានសម្របសម្រួលដោយលេខាធិការដ្ឋាន CEPF ក្នុងសហប្រតិបត្តិការណ៍ជាមួយអង្គការជីវិតបក្សីអន្តរជាតិ នៅឥណ្ឌូចិន អង្គការអភិរក្ស

អន្តរជាតិកម្មវិធីប្រទេសចិន កាឌ័រី ហ្វាម & ប៉ូតានិកហ្គាឌិន (Kadoorie Farm & Botanic Garden) វិទ្យាស្ថាន សាមដ្ឋាណា (Samdhana Institute) និងមូលនិធិអភិវឌ្ឍន៍បរិស្ថានបៃតងយុនណាន (Yunnan Green Environment Development Foundation)។ អ្នកពាក់ព័ន្ធច្រើនជាង ៤៧០ ត្រូវបានពិគ្រោះពិភាក្សាកំឡុងពេលដំណើរការធ្វើបច្ចុប្បន្នភាព ទោះជាតាមរយៈសិក្ខាសាលា ការប្រជុំតូចៗ ឬការឆ្លើយឆ្លងតាមរយៈសារអេឡិចត្រូនិចនានា ជាលទ្ធផលនៅក្នុងឯកសារចុងក្រោយដែលជាផលិតផលប្រកបដោយការសហការយ៉ាងពិតប្រាកដមួយ នៃផ្នែកជាច្រើនរបស់សង្គមស៊ីវិលរដ្ឋាភិបាល និងសហគមន៍ម្ចាស់ជំនួយ។

## យុទ្ធសាស្ត្រវិនិយោគ និង តួនាទី CEPF

ឯកសារស្តីពីប្រពន្ធ័អេកូស៊ីស្ទែម បានឆ្លុះបញ្ចាំងទិដ្ឋភាពជាទូទៅនៃតំបន់ឥណ្ឌូភូមាហាតស្ពតទាក់ទិននិងសារៈសំខាន់ នៃការអភិរក្សជីវៈចំរុះរបស់វា និងសេដ្ឋកិច្ចសង្គម គោលនយោបាយ ព្រមទាំងបរិបទសង្គមស៊ីវិលនានា។ វាកំណត់សណ្ឋាននៃលទ្ធផលការងារអភិរក្សដែលអាចវាស់វែងបាននូវទំហំ ប្រភេទ ទីតាំង ច្រករបៀង (រឺតំបន់ ទេសភាព) និងវាយតំលៃការគម្រាមកំហែងផ្ទាល់សំខាន់ៗទៅលើជំរៈចំរុះ និងបុព្វហេតុបញ្ហារបស់វា។ ការវិភាពពីស្ថានភាពគឺត្រូវបានបញ្ចប់ដោយ ការវាយតំលៃនៃការវិនិយោគការអភិរក្សបច្ចុប្បន្ន ហើយនិងការជំពាក់ទាក់ទងនៃការប្រែប្រួលអាកាសធាតុសំរាប់ការអភិរក្សជីវៈសាស្ត្រចំរុះ។ ឯកសារស្តីពីប្រព័ន្ធអេកូឡូស៊ីបន្ទាប់មកបានបន្ត ដើម្បីបញ្ចាញឲ្យដឹងយ៉ាងច្បាស់ពីយុទ្ធសាស្ត្រវិនិយោគដ៏សំខាន់មួយ សំរាប់អ្នកផ្តល់ជំនួយដែលចាប់អារម្មណ៍នៅក្នុងការគាំទ្រកិច្ចខិតខំអភិរក្សនានា ត្រូវបានដឹកនាំដោយ សង្គមស៊ីវិល។ យុទ្ធសាស្ត្ររួមបញ្ចូលទាំងមុខងារសំរាប់ CEPF នៅកន្លែងដែលការវិនិយោគរបស់ខ្លួនអាចផ្តល់តំលៃបន្ថែមដ៏សម្បើមបំផុត។

ចំណាប់អារម្មណ៍ការវិនិយោគ CEPF គ្របដណ្តប់លើរយៈពេលប្រាំឆ្នាំការកសាងបន្ថែមលើការវិនិយោគនានាកន្លងមក និងការវិនិយោគបង្គ្រប់ដោយប្រភពផ្តល់ជំនួយដ៏ទៃៗទៀត។ ចំណាប់អារម្មណ៍ដាក់បញ្ចូលសេរីនៃការឡានុវត្តភាពយុទ្ធសាស្ត្រថវិកា, បែងចែកទៅក្នុងចំនួននៃអាទិភាពវិនិយោគ កំពុងគ្រោងឡើងសកម្មភាពនានាដែលសមស្របសំរាប់ មូលនិធិ CEPF។ អង្គការសង្គមស៊ីវិលនានា ឬ រូបវន្តបុគ្គលអាចដាក់គម្រោងស្នើសុំដែលនិងជួយអនុវត្តន៍យុទ្ធសាស្ត្រដោយការដោះស្រាយ យ៉ាងហោចណាស់ទិសដៅយុទ្ធសាស្ត្រចំនួនមួយ។ ឯកសារស្តីពីប្រព័ន្ធអេកូឡូស៊ី មិនដាក់

បញ្ចូលទស្សនៈទានគម្រោងជាក់លាក់ឡើយ, ដូចជាក្រុមសង្គមស៊ីវិល និង អភិវឌ្ឍន៍ទស្សនៈទានទាំងនេះជា ផ្នែកនៃសំណើរសុំរបស់ពួកគេសំរាប់ការផ្តល់មូនិធិរបស់ CEPF។

មូលដ្ឋានគ្រឹះនៃជីវសាស្រ្តសំរាប់ការវិនិយោគ CEPF នៅក្នុងតំបន់ឥណ្ឌូភូមាហាតស្ពត គឺត្រូវបានផ្តល់ដោយលទ្ធផលនៃការអភិរក្សទាំងឡាយៈ ក្រុមដែលអាចប្រមាណ ជាតួលេខបាននៃប្រភេទ ទីតាំង និងច្រករបៀងនានា ដែលត្រូវតែត្រូវបានការពារដើម្បី ទប់ទល់នឹងការបាត់បងជីវះចំរុះជាសាកល។ លទ្ធផលនៃការអភិរក្សសំរាប់តំបន់ឥណ្ឌូភូមាត្រូវបានកំណត់នៅកំឡុងពេលរៀបចំនៃឯកសារស្តីពីប្រព័ន្ធអេកូឡូស៊ីដើម។ នៅកំឡុងពេលធ្វើបច្ចុប្បន្នភាពលទ្ធផលនៃការអភិរក្ស ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំង ការប្លាស់ប្តូរនៅក្នុងស្ថានភាពនៃប្រភេទ ទីតាំង និងច្រករបៀងមួយចំនួន ព្រមទាំងភាពធ្វើទៅបាននៃការកែលម្អរទិន្នន័យនានា ជាពិសេសសំរាប់ប្រទេសភូមា។ នៅក្នុង គោលបំណងដើម្បីផ្តល់លទ្ធភាពវិនិយោគដោយ CEPF និងអ្នកផ្តល់ជំនួយដ៏ទៃទៀត ត្រូវបានតំរង់ទិសយ៉ាងមានប្រសិទ្ធភាព, លទ្ធផលប្រភេទ ទីតាំង និងច្រករបៀងនានាត្រូវបានចាត់អាទិភាពតាមរយៈ ដំណើរការពិគ្រោះពិភាក្សារាល់អ្នកពាក់ព័ន្ធដោយអនុវត្តមាត្រដ្ឋានវិនិច្ឆ័យ រួមបញ្ចូលទាំងភាពបន្ទាន់នៃ សកម្មភាពអភិរក្ស និងឱកាសដើម្បីពង្រឹងការខិតខំប្រឹងប្រែងលើការងារអភិរក្សដែលមានស្រាប់។

ជាសរុបលទ្ធផលនៃចំនួន ៧៥៩ប្រភេទ ៥០៩ទីតាំង និង៦៦ច្រករបៀងត្រូវបានតំណាត់សំរាប់ហាតស្ពត។ ក្នុងចំណោមទាំងនេះ ១៥២ប្រភេទ ៧៩ទីតាំង និងបួនច្រករបៀងត្រូបានចាត់ជាអាទិភាពសំរាប់ការវិនិយោគលើការអភិរក្ស។ ប្រភេទអាទិភាពទាំងនេះតំណាងការកើនឡើងជាសំខាន់លើ៦៧ប្រភេទ ដែលត្រូវបានចាត់អាទិភាពនៅក្នុងឯកសារស្តីពីប្រព័ន្ធអេកូឡូស៊ីដើម។ នេះអាចត្រូវបានសន្មតយ៉ាងធំធេង ចំពោះការចាត់បញ្ចូលសំរាប់លើកទីមួយ នៃប្រភេទរុក្ខជាតិជាអាទិភាព និងការរីកឡើងការវិភាគដើម្បីដាក់បញ្ចូលប្រទេសភូមា ជាទីជំរកនៃប្រភេទសត្វមួយក្រុមដែលមិនអាចមាននៅកន្លែងផ្សេងទៀតនៅក្នុងហាតស្ពត។

## ច្រករបៀងជាអាទិភាពសំរាប់ការវិនិយោគរបស់ CEPF នៅឥណ្ឌូភូមាហាតស្ពត




មានការយល់ស្របគ្នាយ៉ាងរឹងមាំក្នុងកំឡុងពេលពិគ្រោះពិភាក្សាជាមួយ អ្នកពាក់ព័ន្ធទាំងឡាយដែល CEPF គួរតែរក្សាអាទិភាពភូមិសាស្ត្របច្ចុប្បន្នរបស់ខ្លួន (ឧទាហរណ៍៖ ទន្លេមេគង្គ និងដៃសំខាន់ៗរបស់វា តំបន់ថ្មកំបោរសីណូប្រទេសវៀតណាមជាដើម) ការបន្ថែមលើអាទិភាពដែលបានបន្ថែមប្រសិនបើធនធានត្រូវបានផ្តល់ឲ្យ។ វាក៏មានការយល់ស្របគ្នាយ៉ាងទូលំទូលាយមួយទៀតដែរ ដើម្បីបន្ថែមបឹងទន្លេសាប និងតំបន់លិចទឹកនៅជុំវិញ ព្រមទាំងប្រជុំភ្នំហៃណានជាច្រករបៀងអាទិភាពបន្ថែម ហើយជាការឆ្លុះបញ្ចាំង លើចន្លោះប្រហោងដែលបានរកឃើញយ៉ាងធំសម្បើម និងការគម្រាមកំហែងពីការអភិវឌ្ឍន៍បែបប្រពលលក្ខណៈកម្មយ៉ាងលឿនកំពុងប្រឈមទៅលើច្រករបៀងទាំងពីរនេះ។ ច្រករបៀងអាទិភាពមិនត្រូវបានកំណត់នៅក្នុងប្រទេសភូមាទេ

ជាទីកន្លែងដែលការវិនិយោគលើការអភិរក្សមានកំរិតទាបហើយទីតាំង និងច្រករបៀង ជាច្រើនកំពុងប្រឈមមុខនឹងការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ ហើយជាការចាំបាច់សំរាប់ យុទ្ធសាស្ត្រដ៏ទៃៗទៀត ជាងទីកន្លែងផ្សេងទៀតនៅក្នុងហាតស្ពត។ ប្រទេសភូមាត្រូវ បានទទួល ស្គាល់ថា ជាទីតាំងភូមិសាស្ត្រអាទិភាពសំរាប់អាទិភាពវិនិយោគនានាដ៏ជាក់ លាក់ និង ពិតប្រាកដ។

អាទិភាពជាខ្លឹមសារសំរាប់ការវិនិយោគលើការអភិរក្សនៅក្នុងហាតស្ពត គឺត្រូវ បានកំណត់តាមរយៈដំណើរការពិគ្រោះពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ផ្អែកទៅលើការវិ ភាគនៃកត្តាគម្រាមកំហែងសំខាន់ៗទៅលើជីវៈចំរុះនៅក្នុងហាតស្ពត និងបុព្វហេតុរបស់- វា។ ការគម្រាមកំហែងឈរលំដាប់ខ្ពស់ជាងគេគឺការបរបាញ់ និងការដាក់អន្ទាក់ សត្វព្រៃ ដែលគម្រាមកំហែងដល់ប្រភេទសត្វនីមួយៗ ជាមួយនឹងការវិនាសផុត ពូជ និងប៉ះពាល់យ៉ាងធំធេងលើប្រព័ន្ធអេកូឡូស៊ីនានា។ ការបំលែងនៃប្រភេទទីជំរក សំរាប់ ដំណាំកសិ–ឧស្សាហកម្ម ដូចជា កៅស៊ូ ដូងប្រេង តែ និងដំណាំសេដ្ឋកិច្ចផ្សេងៗទៀត គឺត្រូវបានកំណត់ជាការគម្រាមកំហែងខ្ពស់បំផុតបន្ទាប់ ត្រូវបានយកលំនាំតាមដំណើរ សាយកូននៃទំនប់វារីអគ្គីសនី ដែលជាការគម្រាមកំហែងដ៏សំខាន់ទៅលើប្រព័ន្ធអេកូឡូ ស៊ីតាមទន្លេ នៅក្នុងហាតស្ពត។ ការយល់ឃើញស្របគ្នាយ៉ាងទូលំទូលាយពីការពិគ្រោះ ពិភាក្សារបស់អ្នកពាក់ព័ន្ធ គឺថាការគម្រាមកំហែងទាំងបីគឺកាត់តែធ្ងន់ធ្ងរឡើងៗ និងនៅ តែបន្តដូច្នេះទៀតទោះជាក្នុងរយៈពេលខ្លីក៏ដោយ។ នៅក្នុងគ្រប់ករណី ការគម្រាមកំ ហែងទាំងនេះ មានការជាប់ទាក់ទងសំរាប់សេដ្ឋកិច្ចជាតិ និងជីវ ភាពរស់នៅរបស់ប្រជា ពលរដ្ឋជនបទ ដែលទាំងពីរនេះអាស្រ័យលើសេវាកម្មផ្តល់ ដោយប្រព័ន្ធអេកូឡូស៊ី ធម្មជាតិ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ក៏ដូចជាការគម្រាមកំហែងផ្សេងៗទៀត ព្រមទាំងដើម្បីចាប់ផ្តើមដោះស្រាយមួយចំនួននៃបុព្វហេតុរបស់វា CEPF បានកំណត់ រូបមន្តមុខងារវិនិយោគមួយដោយការដាក់បញ្ចូល អាទិភាពវិនិយោគចំនួន២១ ចាត់ចូល ក្នុងទិសដៅយុទ្ធសាស្ត្រលេខប្រាំមួយ។ មុខងារ គឺជាលទ្ធផលនៃដំណើរការដ៏ទូលំទូ- លាយ នៃការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ ក៏ដូចជាដៃគូម្ចាស់ជំនួយនានារបស់ CEPF។ មុខងារ CEPF ត្រូវក្នុងយុទ្ធសាស្ត្រវិនិ យោគដ៏សំខាន់មួយ នៃអាទិភាពវិនិយោគចំនួន ៣៨ បានចាត់ចូលក្នុងទិសដៅយុទ្ធ សាស្ត្រលេខ ១១ ។ យុទ្ធសាស្ត្រនេះបង្កើតឲ្យមានមូលដ្ឋានគ្រឹះនៃការវិនិយោគដែល

បានសម្របសម្រួលដោយ CEPF និងម្ចាស់ជំនួយផ្សេងៗទៀត ដែលចាប់អារម្មណ៍នៅក្នុងការគាំទ្រការខិតខំប្រឹងប្រែងលើការងារអភិរក្ស ដែលបានដឹកនាំដោយអង្គការសង្គមស៊ីវិល។

**ទិសដៅជាយុទ្ធសាស្ត្រ និង ការវិនិយោគជាអាទិភាពរបស់ CEPF នៅតំបន់ឥណ្ឌូភូមាហាតស្ពត**

| **ទិសដៅយុទ្ធសាស្ត្ររបស់** | **ការវិនិយោគជាអាទិភាពរបស់** CEPF |
| --- | --- |
| **១. ការការពារជាអាទិភាពដល់ប្រភេទដែលទទួលរងការគំរាមកំហែងជាសាកលដោយកាត់បន្ថយការគម្រាមកំហែង ចំបងៗ** | ១.១ កំលាយការធ្វើអន្តរាគមន៍សាកល្បង ចំនួនប្រជាសាស្ត្រស្ទួលនៃប្រភេទជាអាទិភាពទៅក្នុងកម្មវិធីអភិរក្សយូរអង្វែង |
| | ១.២ អភិវឌ្ឍន៍ដំណោះស្រាយការអនុវត្តន៍ល្អបំផុតទាំងឡាងសំរាប់ការអភិរក្សនៃប្រភេទរងការគម្រាមកំហែង ខ្ពស់ ប្រភេទទឹករស់ក្នុងទឹកសាបដោយតំបន់ |
| | ១.៣ សិក្សាស្រាវជ្រាវលើប្រភេទទទួលរងការ គំរាមកំហែងជាសាកលសំរាប់ដែលជាការចាំបាច់សំរាប់កែលំអរពត៌មានដ៏ទូលំទូលាយលើស្ថានភាព និងរបាយ |
| | ១.៤ គាំទ្រមូនិធិដែលមានស្រាប់ឲ្យក្លាយជាឧបករណ៍មានប្រសិទ្ធភាពសំរាប់ការអភិរក្សនៃប្រភេទជាអាទិភាពនៅក្នុងហាតស្ពត |
| **២. ធ្វើនិទស្សន៍កម្មការឆ្លើយតបតាមបែបបង្កើតថ្មីទៅលើការធ្វើចរាចរ និងការប្រើប្រាស់ ដោយខុសច្បាប់នៃពពួកសត្វព្រៃ** | ២.១ គាំទ្រភ្នាកងារអនុវត្តច្បាប់ដោះស្រាយបណ្តាញជួញដូរសត្វព្រៃកំរិតខ្ពស់ ដោយការណែនាំពួកគេទៅការប្រតិបត្តិល្អបំផុតជាសាកលជាមួយនិងការអង្កេតតាមដាន និងរាយការណ៍ |
| | ២.២ សម្របសម្រួលសហប្រតិបត្តិការណ៍ក្នុងចំណោមភ្នាក់ងារអនុវត្តន៍ច្បាប់នានា និងអ្នកធ្វើសកម្មភាពពីខាងក្រៅដើម្បីកាត់បន្ថយការចរាចរឆ្លងដែននៃពពួកសត្វព្រៃនានា |
| | ២.៣ ធ្វើការជាមួយក្រុមហ៊ុនផ្នែកឯកជនដោយជំរើសដើម្បីលើកំពស់ការបន្សុំការដាក់កំរិតដោយចេតនាទាំងឡាយទៅលើការដឹកជញ្ជូន ការលក់ និងការប្រើប្រាស់ជាអន្តរជាតិ នៃប្រភេទសត្វព្រៃទាំងឡាយ |
| | ២.៤ គាំទ្រការឃោសនា ទីផ្សារសង្គម បណ្តាញទាន់ហេតុការណ៍ និងកម្មវិធីទំនាក់ទំនងអយូរអង្វែងដ៏ទៃទៀតដើម្បីកាត់បន្ថតំរូវការអ្នកប្រើប្រាស់សំរាប់សត្វព្រៃ និងកសាងការគាំទ្រជាសាធារណៈសំរាប់ការអនុវត្តន៍ច្បាប់សត្វព្រៃ |

| ទិសដៅយុទ្ធសាស្ត្ររបស់ | ការវិនិយោគជាអាទិភាពរបស់ CEPF |
|---|---|
| ៥. ផ្តល់អំណាចសហគមន៍មូលដ្ឋានដើម្បីជំរុញនៅក្នុងការអភិរក្ស និងគ្រប់គ្រងតំបន់ជីវៈចំរុះសំខាន់ៗជាអាទិភាពនានា | ៥.១ លើកកំពស់ចំណេះដឹងនានាស្តីអំពីបទដ្ឋានគតិយុទ្ធអភិរក្សជីវៈចំរុះក្នុងចំណោមក្រុមគោលដៅទាំងឡាយនៅឯទីតាំងអាទិភាពទាំងឡាយ |
| | ៥.២ សាកល្បង និងបង្កើតបន្ថែមសហគមន៍ព្រៃឈើ សហគមន៍នេសាទតំបន់ការពារគ្រប់គ្រងដោយសហគមន៍ |
| | ៥.៣ បង្កើតយន្តការសហគ្រប់គ្រងសំរាប់ការពារផ្លូវការដែលផ្តល់លទ្ធភាពការចូលរួមរបស់សហគមន៍នៅក្នុងគ្រប់កំរិតនៃការគ្រប់គ្រង |
| | ៥.៤ ធ្វើការវិភាគចន្លោះប្រហោងនៃតបន់ជីវៈចំរុះសំខាន់ៗ នៅក្នុងប្រទេសភូមា និងគាំទ្រលើការពង្រីកបន្ថែមនៃបណ្តាញតំបន់ការពារដោយប្រើប្រាស់គំរូផ្អែកលើសហគមន៍ |
| ៦. ជំរុញអ្នកធ្វើសកម្មភាពសំខាន់ៗនៅក្នុងសុខដុមនីយកម្មជីវៈចំរុះ សហគមន៍ និងជំរះភាពរស់នៅក្នុងការធ្វើផែកការអភិវឌ្ឍន៍នៅក្នុងច្រករបៀងជាអាទិភាពនានា | ៦.១ គាំទ្រការខិតខំប្រឹងប្រែងរបស់សហគមន៍ស៊ីវិលដើម្បីវិភាគគោលនយោបាយអភិវឌ្ឍន៍ ផែនការ និងកម្មវិធីនានា វាយតំលៃផលប៉ះពាល់លើជីវៈចំរុះ សហគមន៍ និងជីវភាពរស់នៅ និងដាក់សំណើរសុំសេនារីយ៉ូដំណោះស្រាយលើការអភិវឌ្ឍន៍នានាព្រមទាំងវិធានការបន្ធូបន្ថយសមស្របនៅកន្លែង ដែលត្រូវការ |
| | ៦.២ សមាហរណកម្ម ជីវៈចំរុះ និងតំលៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីទាំងឡាយនៃច្រករបៀងជាអាទិភាពនានានៅក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍន៍នៅគ្រប់កំរិត។ |
| | ៦.៣ អភិវឌ្ឍពិធីកា គម្រោងចង្អុលបង្ហាញសំរាប់ការស្តារឡើយវិញនៃអេកូឡូស៊ីដែលធ្វើឲ្យល្អឡើងលើសកម្មភាពជីវៈចំរុះនៃកម្មវិធីព្រៃឈើជាតិ |
| | ៦.៤ ជំរុញប្រព័ន្ធផ្សព្វផ្សាយឲ្យជាឧបករណ៍មួយដើម្បីលើកកំពស់ចំណេះដឹង និងរាយការណ៍ការជជែកពិភាក្សាជាសាធារណៈនៃបញ្ហាបរិស្ថាន |
| ៨.ពង្រឹងសមត្ថភាពសង្គមស៊ីវិលដើម្បីធ្វើការលើជំរះសាស្ត្រចំរុះ សហគមន៍ និងជីវភាពរស់នៅនៅឯកំរិតតំបន់ ជាតិ មូលដ្ឋាន និងបាតក្រោម | ៨.១ គាំទ្រការបង្កើតបណ្តាញសកម្មភាពនានាដែលផ្តល់លទ្ធភាព |
| | ៨.២ ផ្តល់ការគាំទ្រស្នូលសំរាប់ការអភិវឌ្ឍន៍បែបអង្គការនៃអង្គការសង្គមស៊ីវិលក្នុងស្រុក |
| | ៨.៣ បង្កើតយន្តការណ៍លំនៅដ្ឋានច្បាស់លាស់ដើម្បីឲ្យត្រូវទៅនឹងអ្នកស្ម័គ្រចិត្តចំពោះតំរូវការបណ្តុះបណ្តាលរបស់អង្គការសង្គមស៊ីវិលនានា |

| ទិសដៅយុទ្ធសាស្ត្ររបស់ | ការវិនិយោគជាអាទិភាពរបស់ CEPF |
|---|---|
| **១១. ផ្តល់យុទ្ធសាស្ត្រភាពជាអ្នកដឹកនាំ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៃការវិនិយោគលើការអភិរក្ស តាមរយៈក្រុមអនុវត្តន៍ការងារប្រចាំតំបន់** | ១១.១ ធ្វើប្រតិបត្តិការនិងសម្របសម្រួលដំណើរការ និងនីតិវិធិផ្តល់ថវិការបស់ CEPF ដើម្បីធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនៃយុទ្ធសាស្ត្រវិនិយោគនៅពាសពេញតំបន់ហាតស្ពត |
| | ១១.២ កសាងមណ្ឌលតំណាងដ៏ទូលំទូលាយមួយនៃក្រុមសង្គមស៊ីវិលធ្វើការឆ្លងស្ថាប័ន និងព្រំដែននយោបាយឆ្ពោះទៅកាន់ការសំរេចគោលដៅអភិរក្សរួមគ្នាដែលបានបរិយាយនៅក្នុងឯកសារស្តីពីប្រព័ន្ធអេកូឡូស៊ី |

កំណត់ចំណាំះ ដើម្បីសម្របសម្រួលលើសេចក្តីសំអាងមិនស្របគ្នា ការដាក់លេខរៀងទិសដៅយុទ្ធសាស្ត្រ និងអាទិភាពវិនិយោគនានានៅក្នុង មុខងាររបស់ CEPF (ទិសដៅយុទ្ធសាស្ត្រលេខប្រាំមួយ) ហើយទៅតាមនោះដែរនៅក្នុងយុទ្ធសាស្ត្រទាំងស្រុង (ទិសដៅយុទ្ធសាស្ត្រលេខ ១១)។

## សេចក្តសន្និដ្ឋាន

ចំណែកឯនានាភាពនៃប្រភេទ និងប្រភេទមានដោយតំបន់ ឥណ្ឌូភូមាហាតស្ពត គឺជាតំបន់មួយក្នុងចំណោមតំបន់ជីវៈដ៏សំខាន់បំផុតនៅលើភពផែនដី។ ដោយហេតុតែសម្ពាធប្រជាជនដ៏ខ្ពស់ ការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏ឆាប់រហ័ស ព្រមទាំងបែបផែននៃការប្រើប្រាស់មានការផ្លាស់ប្តូរ ប្រព័ន្ធអេកូឡូស៊ីធម្មជាតិនៃតំបន់ហាតស្ពតគឺកំពុង ត្រូវបានដាក់ក្រោមសម្ពាធដែលមានការកើនឡើង។ ចាប់តាំងពីការតាំងចិត្តនៃសមាគមន៍អភិរក្សអន្តរជាតិ គឺត្រូវបានផ្តោតទៅលើហាតស្ពត នៅក្នុងទស្សវត្តន៍ឆ្នាំ១៩៩០ និងការអភិវឌ្ឍន៍គោលនយោបាយបានផ្តល់លទ្ធភាពឲ្យមានលំហូរកើនឡើងនៃជំនួយការណ៍អភិវឌ្ឍក្រៅប្រទេសនានា ប្រទេសច្រើនបំផុតបានទទួលផលប្រយោជន៍ពីការវិនិយោគលើការអភិរក្សដ៏សំខាន់ ជាពិសេសទៅដល់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា។ ផលប៉ះពាល់នានានៃការវិនិយោគនេះរួមមានការពង្រីកនៃតំបន់របស់ប្រទេសនីមួយៗក្រោម (យ៉ាងហោចណាស់មានតែនាម) ការការពារផ្លូវការ និងការអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រអភិរក្សនានានៃប្រសិទ្ធភាពដែលបានចង្អុលបង្ហាញ សូម្បីតែនៅទីកន្លែងដែលមានទំហំកំណត់។

នៅក្នុងឆ្នាំថ្មីៗ ទោះជាយ៉ាងណាក៏ដោយវាមានការកាត់បន្ថយបន្តិចម្តងៗក្នុងចំនោមថវិកាដែលអាចមានសំរាប់ការអភិរក្សជីវៈចំរុះ ម្ចាស់ជំនួយបានបង្វែរការយកចិត្តទុកដាក់ទៅលើបញ្ហាដ៏ទៃៗទៀត (ជាពិសេសច្រើនបំផុតទៅលើការប្រែប្រួលអាកាសធាតុ) ឬ ការលាចេញពីប្រទេសជាច្រើននៅក្នុងហាតស្ពតទាំងស្រុងតែម្តង។ នៅពេលជាមួយគ្នានោះដែរ ការប្លាស់ប្តូរគោលនយោបាយ លក្ខខណ្ឌសេដ្ឋកិច្ចនានា គឺកំពុងសម្របសម្រួលការវិនិយោគលើផ្នែកឯកជនដ៏ធំសម្បើម ក្នុងវិស័យវារីអគ្គីសនី

កសិ-ឧស្សាហកម្ម ការរុករករ៉ែ និងវិស័យឧស្សាហកម្មផ្សេងៗទៀតជាមួយនឹងសក្កដានុពលបំពុលបរិស្ថានដ៏ធំសម្បើម។ ខណៈពេលដែលនិន្នាការទាំងនេះបង្ហាញពីការប្រជែងលើការងារអភិរក្សដ៏សម្បើមគ្មានទីបញ្ចប់ ការអភិវឌ្ឍជាវិជ្ជមានមួយជាការដុះដាលនៃក្រុមសង្គមស៊ីវិលបានជំរុញក្នុងការអភិរក្សជីវៈចំរុះ និងបញ្ហាពាក់ព័ន្ធនានា នៃការអភិវឌ្ឍន៍សមស្រប ការកាត់បន្ថយភាពក្រីក្រ និងសមធម៌សង្គម។

ការលេចឡើងនៃក្រុមទាំងនេះបង្ហាញឲ្យឃើញពីកាឡានុវត្តភាពសំរាប់ CEPF និងអ្នកផ្តល់ជំនួយផ្សេងៗទៀត ដើម្បីគាំទ្រការរួបរួមយ៉ាងទូលំទូលាយនៃសង្គមស៊ីវិល រៀបលំដាប់ពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ទៅដល់អង្គការផ្អែកលើសហគមន៍ និងដើម្បីធ្វើសមាហរណកម្មកញ្ចប់មូនិធិ ដែលដោះស្រាយការប្រជែងលើការងារអភិរក្សចម្បងៗពីពហុកោណ។ យុទ្ធសាស្ត្រវិនិយោគរួមគ្នាបានដាក់ចេញក្នុងឯកសារស្តីពីប្រព័ន្ធអេកូឡូស៊ីនេះ ផ្តល់នូវក្របខ័ណ្ឌការងារមួយសំរាប់ប្រភេទនៃការអភិវឌ្ឍន៍ភាពជាដៃគូ ដែលត្រូវបាន ទាមទានៅកំរិតមូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។ យុទ្ធសាស្ត្រវិនិយោគ គឺសម្រាប់ទាំងពី មានមហិច្ឆតា និងការចង្អុលបង្ហាញនៃទំហំនៃការប្រជែងនឹងការអភិរក្ស ដែលកំពុងប្រឈមទៅនឹងតំបន់ឥណ្ឌូភូមាហាតស្ពត។ ទោះជាយ៉ាងណាក៏ដោយ តាមការបង្កើតការវិនិយោគជាយុទ្ធសាស្ត្រនៅក្នុងសង្គមស៊ីវិល CEPF អាចដាក់ក្នុងទីកន្លែងមូលដ្ឋានគ្រឹះដ៏រឹងមាំមួយនៃសមត្ថភាព ចំនេះដឹង និងការអនុវត្តន៍ល្អដើម្បី ផ្តល់លទ្ធភាពបន្ថែមលើការឆ្លើយតបប្រកបដោយប្រសិទ្ធភាព តាមការពង្រឹងពង្រីក និងជំរុញចលនាអភិរក្ស។